# ទស្សនាវដ្ដី

# សមិទ្ធផលកសិកម្ម

## ប្រចាំឆ្នាំ ២០១៨






## លេខ ពិសេស ទី២


អាសយដ្ឋានលេខ:២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
ទូរស័ព្ទលេខ: (០២៣) ២១១ ៣៥១/ទូរសារលេខ : (៨៥៥)២៣ ២១៧ ៣២០
គេហទំព័រ: http://www.maff.gov.kh
e-mail : info@maff.gov.kh

# មាតិកា ទំព័រ


- អារម្ភកថា............ ii
- របាយការណ៍ស្តីពីសភាពការណ៍កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ប្រចាំឆ្នាំ២០១៨ និងទិសដៅអនុវត្តបន្ត............ ០១

I. **សភាពការណ៍រួម**............ ០១

II. **លទ្ធផលសម្រេចបានតាមបណ្តាផ្នែក**............ ០១

១. ផ្នែកដាំដុះរដូវវស្សាឆ្នាំ២០១៨............ ០១

២. ផ្នែកកៅស៊ូ............ ០២

៣. ផ្នែកកសិ-ឧស្សាហកម្ម............ ០៣

៤. ផ្នែកព្រៃឈើ............ ០៣

៥. ផ្នែកផលិតកម្ម និងបសុព្យាបាល............ ០៥

៦. ផ្នែកជលផល............ ០៦

៧. ផ្នែកវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា............ ០៦

៨. ផ្នែកនីតិកម្មកសិកម្ម............ ០៧

៩. ផ្នែករដ្ឋបាល............ ០៧

១០. ផ្នែកបុគ្គលិក និងអភិវឌ្ឍន៍ធនធានមនុស្ស............ ០៧

១១. មជ្ឈមណ្ឌលព័ត៌មាន និងឯកសារកសិកម្ម............ ០៨

១២. ផ្នែកផែនការ ស្ថិតិ............ ០៨

១៣. ផ្នែកសវនកម្មផ្ទៃក្នុង............ ០៩

១៤. ផ្នែកសហប្រតិបត្តិការអន្តរជាតិ............ ០៩

១៥. ការអប់រំ បណ្តុះបណ្តាលកសិកម្ម............ ០៩

III. **សេចក្តីសន្និដ្ឋាន និងវាយតម្លៃ**............ ១០

VI. **ទិសដៅអនុវត្តបន្ត**............ ១១

- សកម្មភាពថ្នាក់ដឹកនាំក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ............ ១៤
- ការងារអគ្គនាយកដ្ឋានកសិកម្ម............ ៣១
- ការងាររដ្ឋបាលព្រៃឈើ............ ៤៥
- ការងាររដ្ឋបាលជលផល............ ៥៤
- ការងារអគ្គនាយកដ្ឋានកៅស៊ូ............ ៦៣
- ការងារអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ............ ៧៣
- ការងារនាយកដ្ឋានបុគ្គលិក និងអភិវឌ្ឍន៍ធនធានមនុស្ស............ ៨០
- ការងារនាយកដ្ឋានផែនការ-ស្ថិតិ............ ៨៩
- ការងារនាយកដ្ឋាននីតិកម្មកសិកម្ម............ ៩២
- ការងារវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា............ ៩៩
- ការងារសាកលវិទ្យាល័យភូមិន្ទកសិកម្ម............ ១០៦
- ការងារសាលាជាតិកសិកម្មព្រែកលៀប............ ១១១

# អារម្ភកថា

វិស័យកសិកម្មបានសម្រេចលទ្ធផលការងារ ក្នុងឆ្នាំ២០១៨ ទៅតាមផែនការសកម្មភាពនៃអនុវិស័យនីមួយៗ មានផ្នែកជាច្រើនដូចជា៖

**ដំណាំស្រូវ៖** លទ្ធផលនៃការភ្ជួររាស់សម្រេចបានចំនួន ៣ ០០៣ ២២៣ ហ.ត ក្នុងនោះភ្ជួររាស់ដោយកម្លាំងគោ-ក្របី សម្រេចបានចំនួន១០៧ ១១៤ ហ.ត និងភ្ជួររាស់ដោយគ្រឿងយន្តបានចំនួន ២ ៨៩៦ ១០៩ ហ.ត លើសឆ្នាំមុន ៥៧ ៨៦២ ហ.ត។ ផ្ទៃដីសាបសម្រេចបានចំនួន ៣២ ៧៦៤ ហ.ត តិចជាងឆ្នាំមុនចំនួន៩ ១៦៩ ហ.ត ផ្ទៃដីស្ទូង និងព្រោះបានចំនួន ២ ៧៣៥ ៨៤០ ហ.ត ស្មើនឹង ១០៨,៨៣% នៃផែនការ ២ ៥១៣ ៨៩៥ ហ.ត លើសឆ្នាំមុនចំនួន ៧៨ ០៧២ ហ.ត។ ការនាំចេញអង្ករសម្រេចបានចំនួន១២៨ ៩៨៥ តោនដែលមានការកើនឡើងចំនួន ៥៥ ៥៤៣ តោន(+៤៣% ) ធៀបនឹងបរិមាណការនាំចេញក្នុងខែធ្នូ ឆ្នាំ២០១៧។ សរុបរយៈពេល ១២ខែ ឆ្នាំ២០១៨ នាំចេញបានចំនួន៦២៦ ២២៥តោន ទៅកាន់ទិសដៅចំនួន៦១ ប្រទេស ។

**ដំណាំរួមផ្សំ និងដំណាំឧស្សាហកម្ម៖** សម្រេចបានចំនួន ៥៥ ៥៤៣ ហ.ត ស្មើនឹង៦៤,៤៩% នៃផែនការ ៣១ ៥៨៤ ហ.ត លើសឆ្នាំមុនចំនួន៨ ៦៣៦ ហ.ត និងដំណាំឧស្សាហកម្មសម្រេចបានចំនួន ៥៦ ៦០៥ ហ.ត ស្មើនឹង ៥៣ ០៤% នៃផែនការ ១០៦ ៧១៣ ហ.ត លើសឆ្នាំមុនចំនួន ២៨ ៤៤២ ហ.ត។

**ផ្នែកកៅស៊ូ៖** ផ្ទៃដីអាជីវកម្ម ចម្ការកៅស៊ូកសិឧស្សាហកម្មរដ្ឋអនុវត្តបានចំនួន៦៧០ ហ.ត លើផ្ទៃដីចម្ការកៅស៊ូសរុបចំនួន ៨០១ ហ.ត ផលិតផលប្រចាំឆ្នាំអនុវត្តបានចំនួន៥៣៨ តោន បញ្ចេញលក់ប្រចាំឆ្នាំបានចំនួន៥៥០តោន។ ផ្ទៃដីអាជីវកម្មចម្ការកៅស៊ូកសិឧស្សាហកម្មឯកជនអនុវត្តបានចំនួន ៣៦ ៥២១ ហ.ត លើផ្ទៃដីសរុបចំនួន ៥០ ២១១ ហ.ត ផលិតផលប្រចាំឆ្នាំអនុវត្តបានចំនួន ៤១៨៥៤តោននិងបញ្ចេញលក់ប្រចាំឆ្នាំបានចំនួន៤២៣៧៩តោន។ផ្ទៃដីអាជីវកម្មក្រុមហ៊ុនវិនិយោគលើសម្បទានដីសេដ្ឋកិច្ចនិងចម្ការកៅស៊ូគ្រួសារអនុវត្តបានចំនួន១៦៤ ៧៥៨ ហ.ត លើផ្ទៃដីចម្ការកៅស៊ូសរុបចំនួន៣៨៥ ៦៧០ ហ.ត ផលិតផលប្រចាំឆ្នាំអនុវត្តបានចំនួន១៧៧ ៧០៨ តោន និងបញ្ចេញលក់បានចំនួន១៧៤ ៥៧១ តោន។

**ផ្នែកផលិតកម្ម និងបសុព្យាបាល៖** កំពុងពង្រឹងការងារ ផលិតកម្មសត្វ តាមរយៈការបណ្តុះបណ្តាលគ្រូបង្គោល លើជំនាញបច្ចេកទេសចិញ្ចឹមសត្វ ។ កែលម្អពូជ បច្ចុប្បន្ននៅស្ថានីយ៍ពូជគោភ្នំតាម៉ៅមានគោសរុបចំនួន១០៧ ក្បាល ក្នុងនោះគោប្រាម៉ាន់កាត់មានចំនួន ៣៣ ក្បាល កូនគោបៅដោះមានចំនួន៣៤ ក្បាល គោកំផែងសែនមានចំនួន ៤០ ក្បាល ដោយឡែកនៅស្ថានីយ៍ពិសោធន៍ពូជជ្រូកកម្ពុជា-ចិន មានជ្រូកសរុបចំនួន២០៣ក្បាល និងចំណីសត្វប្រកបដោយគុណភាព លូតលាស់ឆាប់រហ័ស ធន់នឹងជំងឺ និងផ្តល់ប្រាក់ចំណូលខ្ពស់ក្នុងគ្រួសារ។ លទ្ធផលត្រួតពិនិត្យ បង្ក្រាបបទល្មើសសត្វ និងអនុវត្តជីវសុវត្ថិភាព ចុះបាញ់ថ្នាំរំងាប់មេរោគចំនួន៤៥ ៥៣៦ លើក នៅតាមកសិដ្ឋានកន្លែងចិញ្ចឹមសត្វ សត្តឃាតដ្ឋាន ទីកន្លែងលក់បក្សី និងកន្លែងផ្ទុះជំងឺសត្វទូទាំង២៥ រាជធានី-ខេត្ត-ក្រុង។ បានកម្ទេចចោលផលិតផលខូចគុណភាពតាមវិធានការបសុពេទ្យសរុបចំនួន ៦៣៨,០គីឡូក្រាម និងដាក់ពិន័យទៅតាមច្បាប់ស្តីពីសុខភាពសត្វ និងផលិតកម្មសត្វ ចុះអង្កេតតាមដាន និងយកវត្ថុវិភាគនៅតាមកន្លែងដែលមានសត្វឈឺងាប់ ឬនៅតាមសត្តឃាតដ្ឋានសរុបចំនួន ១៣ ៤១៨ វត្ថុវិភាគ ដើម្បីធ្វើការវិភាគរកប្រភេទមេរោគបង្កជំងឺ។

**ផ្នែកព្រៃឈើ៖**

- បង្កើត និងគ្រប់គ្រងតំបន់ព្រៃសហគមន៍ចំនួន ៣១ មានផ្ទៃដីព្រៃសរុបទំហំ ៣៥ ៨៩៦,៦៦ ហ.ត
- បានចុះកិច្ចព្រមព្រៀងព្រៃសហគមន៍ចំនួន៤ មានផ្ទៃដីទំហំ២៧ ៨៩១ ហ.ត
- ផ្តល់បណ្ណសម្គាល់សិទ្ធិប្រើប្រាស់រណាយន្តសរុបចំនួន ៧៧ គ្រឿង និងយានយន្តចំនួន៤៥ គ្រឿង
- សហការជាមួយរដ្ឋបាលព្រៃឈើមូលដ្ឋាន ចុះអន្តរាគមន៍ទប់ស្កាត់ និងបង្ក្រាបការជួញដូរសត្វព្រៃចំនួន ១០ លើក
- បានធ្វើជំរឿនសត្វស្វានៅតាមទីសាធារណៈនិងតំបន់សួនសត្វនៅតាមបណ្តារាជធានី-ខេត្ត-ក្រុង មានស្វាចំនួន២ ៩៧០ក្បាល
- ចុះសិក្សាស្រាវជាវនិងតាមដានវត្តមានសត្វព្រៃចំនួន៨លើកនៅតាមបណ្តាខេត្តដោយបានកត់ត្រាប្រភេទសត្វសំខាន់បានចំនួន ២៣៦ប្រភេទ ក្នុងនោះមានថនិកសត្វចំនួន៦១ប្រភេទ សត្វស្លាបចំនួន១៤៧ ប្រភេទ និងឧរង្គសត្វចំនួន២៨ប្រភេទ
- ក្រុមហ៊ុនចំនួន៦ ដែលមានកសិដ្ឋានស្រាវជ្រាវចិញ្ចឹម និងបង្កាត់ពូជសត្វស្វាក្តាម យកកូននាំចេញចំនួន ៧ ទីតាំង នៅរាជធានីភ្នំពេញ ខេត្តកំពង់ធំ កំពង់ចាម កំពង់ស្ពឺ ពោធិ៍សាត់ និងខេត្តកំពង់ឆ្នាំង មានស្វាក្តាមសរុបចំនួន ៥៣ ៩២៤ ក្បាល ក្នុងនោះកូនកើតក្នុងខែមានចំនួន ១១ ៨១៣ ក្បាល ដឹកជញ្ជូនក្នុងស្រុកបានចំនួន២ ១៣១ ក្បាល និងនាំចេញបានចំនួន ១០ ៧៦២ ក្បាល ។

- ឧទ្យានសួនសត្វ និងមជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃភ្នំតាម៉ៅមានសត្វព្រៃសរុបចំនួន១ ៦២៩ ក្បាល សង្គ្រោះសត្វថ្មីចំនួន ១ ៧៦៩ក្បាល

- **ការដាំដើមឈើ៖** បានបង្កើតស្ថានីយ៍ផ្សព្វផ្សាយ និងស្តារព្រៃឈើ នៅលើដីសាធារៈរបស់រដ្ឋដែលមានទំហំ៧ ២៤៣ ៦០៥ម២ និងមានវិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុចំនួន២០៣ ប័ណ្ណ

- បានស្នើសុំចុះបញ្ជីដីរដ្ឋ និងរៀបចំឯកសារស្នើសុំបង្កើតស្ថានីយ៍ផ្សព្វផ្សាយ និងស្តារព្រៃឈើចំនួន៣៨ ទីតាំង មានផ្ទៃដីសរុបទំហំ២១១ ៩២២,៣១ ហ.ត

- អនុវត្តគម្រោងដាំឈើជាចម្ការថ្មីទំហំ១៥២ ហ,ត នៅស្ថានីយ៍ផ្សព្វផ្សាយ និងស្តារព្រៃឈើចំនួន២ទីតាំង

- **ចំណូលព្រៃឈើ៖** ពីថ្លៃសួយសារផល អនុផលព្រៃឈើសរុប ១៨ ០៣៩ ៦៩២ ៤៧៦ រៀល និង១៣៤ ០៥២,១៩ ដុល្លារសហរដ្ឋអាមេរិក។

**ផ្នែកជលផល**: ផលត្រីប្រមូលបានសរុបចំនួន ៩១០ ១៥៣ តោន កើនលើសឆ្នាំមុនចំនួន៥៣ ៨៩០តោន ក្នុងនោះផលនេសាទទឹកសាបមានចំនួន៥៣៥ ០០៥តោន ផលនេសាទសមុទ្រមានចំនួន១២១ ១០០ តោន និងផលវារីវប្បកម្មមានចំនួន២៥៤ ០៤៨តោន

- បទល្មើសនេសាទជលផលសរុបមានចំនួន៣ ១៦៦ករណី បើប្រៀបធៀបទៅជាមួយឆ្នាំមុនមានការថយចុះចំនួន៧៥៩ករណី ក្នុងនោះបានបំផ្លាញចោលវត្ថុតាងចំនួន ២ ៩៧៨ ករណី ពិន័យអន្តរការណ៍ចំនួន១១៤ករណី និងបានលែងត្រីចម្រុះទៅក្នុងធម្មជាតិបានចំនួន៧២ ៩៦៧ គ.ក្រ។

ផ្នែកផ្សេងៗជាច្រើន កំពុងខិតខំជំរុញដំណើរការប្រកបដោយមោទនភាព និងការទទួលខុសត្រូវខ្ពស់ជាបន្តទៀតនៅឆ្នាំបន្ទាប់ហើយសមិទ្ធផលដ៏ល្អប្រសើរសម្រេចបានក្នុងឆ្នាំ២០១៨នេះគឺបានមកពីការដឹកនាំដ៏ឈ្លាសវៃរបស់ឯកឧត្តមរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ព្រមទាំងមានការខិតខំប្រឹងប្រែងរបស់ថ្នាក់ដឹកនាំ និងមន្ត្រីរាជការ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ គ្រប់លំដាប់ថ្នាក់ជួយគាំទ្រ និងមានប្រជាកសិករចូលរួមព្រមទាំងមានកិច្ចសហប្រតិបត្តិការពីក្រសួង ស្ថាប័នពាក់ព័ន្ធអាជ្ញាធរថ្នាក់ក្រោមជាតិដៃគូអភិវឌ្ឍន៍ វិស័យឯកជន និងអង្គការមិនមែនរដ្ឋាភិបាលនានា។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សូមថ្លែងអំណរគុណ ចំពោះរាជរដ្ឋាភិបាលកម្ពុជា ក្រសួង ស្ថាប័ន អាជ្ញាធរមូលដ្ឋាន គ្រប់ជាន់ថ្នាក់ ដៃគូអភិវឌ្ឍន៍ វិស័យឯកជន ប្រជាកសិករ និងអង្គការមិនមែនរដ្ឋាភិបាលនានា ដែលបានជួយឧបត្ថម្ភគាំទ្រ និងចូលរួមវិភាគទានធាតុចូលកសិកម្មដ៏ថ្លៃថ្លា ក្នុងការអភិវឌ្ឍវិស័យកសិកម្ម៕



ម.គ.ឯ.ក AIDOC
Code: 067-002
Date:
Donated by:

# សួស្ដីឆ្នាំថ្មី!

សូមបួងសួងដល់វត្ថុស័ក្តិសិទ្ធក្នុងលោក
ប្រោសប្រទានពរជ័យ សិរីមង្គល វិបុលសុខ មហាប្រសើរជូនចំពោះ

សម្ដេច ព្រះអង្គម្ចាស់ ព្រះអង្គម្ចាស់ក្សត្រិយ៍ ឯកឧត្តម
អ្នកឧកញ៉ា លោកជំទាវ លោក លោកស្រី
ក្នុងឱកាសចូលឆ្នាំថ្មី ប្រពៃណីជាតិ ឆ្នាំកុរ
ឯកស័ក ព.ស ២៥៦២-២៥៦៣ ត្រូវនឹង គ.ស ២០១៩

សូមប្រកបទៅនឹងពុទ្ធពរទាំងបួនប្រការគឺ:
អាយុ វណ្ណៈ សុខ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

ពីឯកឧត្តម វេង សាខុន
រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
ព្រមទាំងថ្នាក់ដឹកនាំ និងមន្ត្រីរាជការទាំងអស់
ក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។



**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ក ស ក

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

# របាយការណ៍
# ស្តីពី
# សភាពការណ៍កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ប្រចាំឆ្នាំ២០១៨ និងទិសដៅអនុវត្តបន្ត

## I- សភាពការណ៍រួម

នៅក្នុងឆ្នាំ២០១៨នេះ តាមការកត់សម្គាល់ឃើញថា ការងារបង្កបង្កើនផលស្រូវរដូវវស្សានៅទូទាំងប្រទេសបានបញ្ចប់ហើយដោយសម្រេចបានចំនួន ២ ៧៣៥ ៨៤០ហ.ត ស្មើនឹង១០៨,៨៣% នៃផែនការ ២ ៥១៣ ៨៩៥ហ.ត។ ការប្រើប្រាស់គ្រឿងយន្តសម្រាប់ការរៀបចំដីផលិតកម្មដំណាំស្រូវគឺស្មើនឹង៩៦,៤៣% ធៀបនឹងការប្រើប្រាស់ដោយគោ-ក្របីមាន ៣,៥៧% រីឯការចូលរួមទប់ស្កាត់បទល្មើសផ្សេងៗទៀតជាពិសេសបទល្មើសព្រៃឈើ បទល្មើសជលផល ក្រោមកិច្ចសហការជាមួយគណៈកម្មការអន្តរក្រសួង ព្រមទាំងបទល្មើសចលនាសត្វដោយខុសច្បាប់ត្រូវបានអនុវត្តប្រកបដោយប្រសិទ្ធភាព។ ចំណែកឯការចុះធ្វើអធិការកិច្ចជី-ថ្នាំកសិកម្ម ការជំរុញការងារផ្សព្វផ្សាយកសិកម្មតាមគ្រប់រូបភាពបានប្រព្រឹត្តទៅក្រោមកិច្ច-សហប្រតិបត្តិការយ៉ាងល្អប្រសើរជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ និងសហគមន៍កសិកម្មទៅតាមភារកិច្ចក្នុងស្មារតីទទួលខុសត្រូវ។ ទន្ទឹមនឹងនេះ ព្រឹត្តិការណ៍សំខាន់ៗក្នុងឆ្នាំ២០១៨នេះគឺ ការរៀបចំវេទិកាកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ការរៀបចំវេទិកាកសិករឆ្នើម ការរៀបចំពិធីសន្និបាតកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ការរៀបចំកិច្ចប្រជុំសំខាន់ៗ ការទទួលជួបភ្ញៀវជាតិ-អន្តរជាតិ ការរៀបចំសិក្ខាសាលា វគ្គបណ្តុះបណ្តាលទាំងក្នុង និងក្រៅប្រទេសជាច្រើន រួមទាំងការបន្តរៀបចំលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនានាផងដែរ។

រីឯលទ្ធផល និងសកម្មភាពការងារសំខាន់ៗតាមផ្នែកផ្សេងៗឆ្លើយតបទៅនឹងការអនុវត្តផែនការប្រចាំឆ្នាំ រួមទាំងការចូលរួមអនុវត្តកំណែទម្រង់ស៊ីជម្រៅរបស់រាជរដ្ឋាភិបាលដែលសម្រេចបានក្នុងឆ្នាំ២០១៨នេះ មានដូចតទៅ៖

## II- លទ្ធផលសម្រេចបានតាមបណ្តាផ្នែក

### ១ ផ្នែកដាំដុះរដូវវស្សាឆ្នាំ២០១៨

#### ១.១ ផលិតកម្មដំណាំស្រូវរដូវវស្សា

ល្បឿនការងារបង្កបង្កើនផលដំណាំស្រូវរដូវវស្សាគិតត្រឹមថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៨ មានលម្អិតដូចខាងក្រោម៖

- ផ្ទៃដីភ្ជួររាស់សម្រេចបានចំនួន ៣ ០០៣ ២២៣ហ.ត ក្នុងនោះភ្ជួររាស់ដោយគោ-ក្របីមានចំនួន ១០៧ ១១៤ហ.ត និងដោយគ្រឿងយន្តមានចំនួន ២ ៨៩៦ ១០៩ហ.ត លើសឆ្នាំមុនចំនួន ៥៧ ៨៦២ហ.ត
- ផ្ទៃដីសាបសម្រេចបានចំនួន ៣២ ៧៦៤ហ.ត តិចជាងឆ្នាំមុនចំនួន ៩ ១៦៩ហ.ត
- ផ្ទៃដីស្ទូង និងព្រោះសម្រេចបានចំនួន ២ ៧៣៥ ៨៤០ហ.ត ស្មើនឹង ១០៨,៨៣% នៃផែនការ ២ ៥១៣ ៨៩៥ហ.ត លើសឆ្នាំមុនចំនួន ៧៨ ០៧២ហ.ត។

#### ១.២ ការងារប្រមូលផលស្រូវរដូវវស្សាឆ្នាំ២០១៨

ការងារប្រមូលផលស្រូវរដូវវស្សាសម្រេចបានចំនួន ២ ៤២០ ៣៧៦ហ.ត ដោយទទួលបានបរិមាណផលសរុបចំនួន ៧ ៤៣៥ ២៤៦តោន លើសឆ្នាំមុនចំនួន ២៥០ ៣៤០តោន។ ទិន្នផលគិតជាមធ្យម ៣,០៧២តោន/ហ.ត លើសឆ្នាំមុនចំនួន ៥៧គ.ក្រ/ហ.ត។

#### ១.៣ ផលិតកម្មដំណាំស្រូវរដូវប្រាំងឆ្នាំ២០១៨-២០១៩

ល្បឿនការងារបង្កបង្កើនផលដំណាំស្រូវរដូវប្រាំងគិតត្រឹមថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៨ មានលម្អិតដូចខាងក្រោម៖

- ផ្ទៃដីភ្ជួររាស់សម្រេចបានចំនួន ៤៩៣ ០៤០ហ.ត ក្នុងនោះភ្ជួររាស់ដោយគោ-ក្របីមានចំនួន ៦ ២០៤ហ.ត និងដោយគ្រឿងយន្តមានចំនួន ៤៨៦ ៨៣៦ហ.ត លើសឆ្នាំមុនចំនួន ១៤៤ ៦៩៨ហ.ត